# តើយើងអាចរំពឹងអ្វីពីព្រះជាម្ចាស់នៅពេលនេះ ?
# សេចក្តីពិតខាងវិញ្ញាណ ទី២៖ ចូររំពឹងថាព្រះកំពុងតែធ្វើការនៅក្នុងជីវិតរបស់អ្នក ហើយដឹកនាំ និងតម្រូវផ្លូវអ្នកជានិច្ច។



*កំពុងអង្គុយសញ្ជឹងគិត បន្ទាប់ពីបានធ្វើដំណើរអស់៥០០ម៉ាយល៍ នៅ Canino (Finisterre, ប្រទេសអេស្ប៉ាញ)*

ពេលនោះគឺដើមខែមិនា។ វិបត្តិកូវីដ១៩ បានបង្កទុក្ខសោកទូទាំងសាកលលោកទៅហើយ។ គ្មានករណីណាដែលត្រូវបានបញ្ជាក់ថាមាននៅប្រទេសមីយ៉ាន់ម៉ាទេ ប៉ុន្តែ មេរោគកូរ៉ូណាកំពុងឆ្លងរាលដាល ទូទាំងពិភពលោក ហើយក៏កំពុងតែសំដៅឆ្ពោះទៅកាន់រដ្ឋកំណើតរបស់ខ្ញុំ គឺ មីនីសូតា។ ខ្ញុំបាននៅឯទីក្រុងយ៉ាងហ្គុន (Yangon) ដោយកំពុងតែរៀបចំព័ន្ធកិច្ចសម្រាប់រយៈពេលមួយខែ ជាមួយគ្រូគង្វាលប្រមាណ២០០នាក់ ក្នុងកម្មវិធីសិក្ខាសាលារយៈពេលបីសប្តាហ៍ នៅ Mandalay, Kanpetlet (រដ្ឋ ជីន ភាគខាងត្បូង) ហើយនៅម៉ុំ Sittwe (រដ្ឋ រ៉ាក់ឃីន)។ តើខ្ញុំគួរធ្វើដូចម្តេច? តើខ្ញុំគួរតែរកវិធីគេចខ្លួនឲ្យមានសុវត្ថិភាព ហើយចាកចេញពីប្រទេសជាបន្ទាន់ឬយ៉ាងណា? តើធ្វើដូចម្តេច ទើបអាចមានជីវិតរស់ ដើម្បីបន្តតួនាទីជាប្តី និងជាឪពុក? តើធ្វីអ្វីទើបប្រកបដោយទំនួលខុសត្រូវខ្ពស់បំផុត ក្នុងនាមជាអ្នកបម្រើព្រះ និងជាគ្រូបង្រៀន? តើខ្ញុំគួរបន្ទះមានះបើកសិក្ខាសាលាទាំងនេះ ដើម្បីជាប្រយោជន៍ដល់គ្រូគង្វាល ដែលធ្លាប់បានរំពឹងល្អការបណ្តុះបណ្តាលនេះសម្រាប់ខ្លួនឯងផង និងសម្រាប់ជាប្រយោជន៍ដល់ពួកជំនុំ ដែលពួកគាប់បម្រើផង ឬមួយក៏ត្រូវត្រឡប់ទៅស្រុកវិញ កាន់តែឆាប់តាមដែលអាចធ្វើបាន?

គិតចុះគិតឡើង ចម្លើយហាក់ដូចជាកាន់តែច្បាស់។ ប៉ុន្តែ ម្តងៗ ក៏ដូចជាសព្វមួយដង ពេលស្ថិតក្នុងស្ថានភាពនៃវិបត្តិ និងភាពមិនប្រាកដប្រជា ជម្រើស "ត្រឹមត្រូវ" មិនលេចមកឲ្យឃើញជាក់ស្តែងទេ។ ក្នុងស្ថានភាពនេះ សម្រាប់ខ្ញុំតម្លៃនៃការមើលថែគ្រួសារ ការការពារសុខភាពផ្ទាល់ខ្លួន និងការបំពេញការប្តេជ្ញាចិត្ត ព្រមទាំងការទទួលខុសត្រូវចំពោះព័ន្ធកិច្ច កំពុងតែជាទម្នាស់ដ៏ពុះកញ្ជ្រោល នៅក្នុងខ្លួនខ្ញុំ។

សម្រាប់មនុស្សយើងភាគច្រើន យើងអធិស្ឋានសុំការដឹកនាំ ក្នុងកាលៈទេសៈបែបនេះ ប៉ុន្តែ ហាក់ដូចជាមិនទទួលបានចម្លើយភ្លាមៗសោះ។ ភាពចលាចលខាងក្នុងខ្លួនយើង ធ្វើឲ្យយើងមានភាពចប់បារម្ភ ឬច្របូកច្របល់។ ប្រ

សិនបើវិបត្តិនោះធំធេង យើងមិនសូវធ្វើការសម្រេចចិត្តក្រោមការដឹកនាំនៃព្រះវិញ្ញាណប៉ុន្មាន គឺយើងច្រើនតែឆ្លើយតប ដោយការវាយបក ឬគេចវេស ជាការឆ្លើយតបដែលជាប់គាំងមួយ។ នោះមានន័យថា យើងប្រហែលជាធ្វើមិនអើពើ ចំពោះគ្រោះថ្នាក់ដោយងងើល ហើយវាយបកចំពោះបញ្ហានោះមួយទំហឹង តែទំនងជាធ្វើវាដោយងងឹតងងល់ ឬដោយល្ងីល្ងើបំផុត។ ឬបើពុំដូច្នោះទេ យើងប្រហែលជារត់គេច ឲ្យបានកាន់តែលឿនតាមដែលអាចធ្វើបាន ទាល់តែក្រោយមក ទើបដឹងខ្លួនថា យើងមានភាពស្លន់ស្លោរពេកហើយ។ គ្រោះថ្នាក់នោះ វាអាចមិនធំធេង ដូចដែលយើងភ័យខ្លាចវានោះទេ ហើយយើងក៏ខកឱកាសដើម្បីបម្រើ អស់អ្នកដែលពឹងផ្អែកលើយើង។ ឬមួយក៏ យើងអាចប្រែក្លាយជាថប់បារម្ភពេក ទើបធ្វើឲ្យយើងជាប់គាំង មិនអាចធ្វើការសម្រេចចិត្តកើត ប៉ុន្តែ តាមរយៈការមិនសម្រេចចិត្តរបស់យើងនោះ គឺយើងបរាជ័យក្នុងការចាត់វិធានការណ៍ឆ្លើយតប ដោយឈ្លាសវៃ និងទាន់ពេលវេលាមួយ។ បើមានសភាវគតិណាមួយ ក្នុងចំណោមការវាយបក ឬគេចវេស ឬក៏ជាប់គាំងនេះ សុទ្ធតែជាករណីធម្មតា និងទូទៅសម្រាប់យើង ហើយជួនកាលវាថែមទាំងអាចមានប្រយោជន៍ ក្នុងពេលដែលមានគ្រោះថ្នាក់ក៏អាចថាបាន។ ប៉ុន្តែ ការធ្វើការសម្រេចចិត្ត ដែលដឹកនាំដោយព្រះវិញ្ញាណពឹងផ្អែកលើកត្តាផ្សេងទៀត មិនត្រឹមតែលើការជំរុញទឹកចិត្ត វិចារណញ្ញាណ ឬភាពឈ្លាសវៃផ្ទាល់ខ្លួនប៉ុណ្ណោះទេ។

**សេចក្តីពិតខាងវិញ្ញាណ ទី២៖ ចូររំពឹងថាព្រះកំពុងតែធ្វើការក្នុងជីវិតរបស់អ្នក ដោយដឹកនាំ និងតម្រង់ផ្លូវអ្នក ដូច្នេះចូររស់នៅតាមការរបស់ព្រះចុះ។** (សុភាសិត ៣:៥-៦; យ៉ាកុប ១:៥-៦)



***តើការទុកចិត្តព្រះមានលក្ខណៈដូចម្តេច?***

ខណៈពេលដែលភរិយារបស់ខ្ញុំ ហើយក្រុមបុគ្គលិក និងដៃគូព័ន្ធកិច្ច ព្រមទាំងខ្ញុំផ្ទាល់ សញ្ជឹងគិតទាំងឈឺចាប់ចំពោះសំណួរទាំងប៉ុន្មាននេះ ព្រះវិញ្ញាណបរិសុទ្ធរំឭកខ្ញុំថា ខ្ញុំត្រូវតែទុកចិត្តថាព្រះទ្រង់នឹងដឹកនាំយើង ក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយ។ ជំនួសដោយការត្រូវទទួលរងទម្ងន់ នៃអស់ទាំងសំណួរគ្មានចម្លើយទាំងនេះ នៅលើស្មារបស់ខ្ញុំផ្ទាល់ ខ្ញុំប្រែជាមានអារម្មណ៍ធូរស្បើយ ដោយនឹកចាំថា មិនមែនមានតែខ្ញុំម្នាក់ឯងទេ ដែលស្ថិតនៅក្នុងស្ថានភាពដ៏គួរឲ្យថប់បារម្ភនេះ និងមិនប្រាកដប្រជានេះ។ ព្រះទ្រង់គង់នៅជិតបង្កើយ ដើម្បីប្រុងចាំជួយជានិច្ច។ ខ្ញុំត្រូវតែជឿសេចក្តី

សន្យានេះ ហើយប្រព្រឹត្តិខ្លួនដូចការដែលបានជឿជាក់មែន។ ស្តេចសាឡូម៉ូន បានថ្លែងយ៉ាងដូច្នេះ កាលពីជិត៣០០០ឆ្នាំកន្លងទៅហើយថា៖

ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។
ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ
នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង។
សុភាសិត ៣:៥-៦

ប្រសិនបើយើងពឹងផ្អែក (ទាំងស្រុង) លើប្រាជ្ញា និងយោបល់របស់យើងផ្ទាល់ ក្នុងពេលដែលមានវិបត្តិ ឬពេលពិបាកធ្វើការសម្រេច នោះយើងងាយវិភាគខុសចំពោះស្ថានការណ៍ ឬក៏ងាយឈានចូលទៅធ្វើការសន្និដ្ឋានដែលខុស។ ផ្ទុយទៅវិញ ផ្លូវនៃសេចក្តចេះដឹងតាមព្រះគម្ពីរ គឺត្រូវពឹងផ្អែកពេញទំហឹងលើព្រះ ដែលជាអ្នកដឹកនាំ និងជាអ្នកតម្រង់ផ្លូវ។ ទីមួយ យើងត្រូវបានប្រាប់ឲ្យ "ទទួលស្គាល់" ព្រះជាអម្ចាស់ នៅគ្រប់ទាំងផ្លូវរបស់យើង នោះមានន័យថា យើងត្រូវតែបន្ថយល្បឿន ហើយបន្ទាបខ្លួន និងចុះចូលតាមបំណងព្រះហឫទ័យនៃព្រះ មិនមែនតាមចិត្តយើងទេ។ បន្ទាប់មក យើងត្រូវ "ទុកចិត្តដល់ព្រះអម្ចាស់ ឲ្យអស់អំពីចិត្ត" មានន័យថា យើងត្រូវទីពឹងលើព្រះវិញ្ញាណបរិសុទ្ធ ឲ្យដឹកនាំ និងតម្រង់ផ្លូវយើង ខណៈពេលយើងយើងបន្តដំណើរការប្រមូលព័ត៌មាន និងថ្លឹងថ្លែងគំនិតទាំងប៉ុន្មានរបស់យើង។ ប្រាកដណាស់ ការទុកចិត្តបែបនេះ មិនមែនជាការទុកចិត្តដែលអសកម្មនោះទេ។ តាមពិត ក្នុងនោះរួមការតោងជាប់តាមព្រះយ៉ាងសកម្ម ដើម្បីឲ្យប្រាជ្ញាដែលអាចមើលឃើញហេតុការណ៍បានច្បាស់លាស់ ហើយបានយល់ដឹងកាន់ប្រសើរ នូវអ្វីដែលយើងមិនអាចមើលឃើញដោយភ្នែក ឬដោយគំនិតរបស់យើងបាន។ ដើម្បីយើងអាចមានសង្ឃឹមថា យើងអាចធ្វើការសម្រេចចិត្តបានល្អបំផុត គឺមានតែតាមរយៈដំណើរការណ៍នៃការចេះដឹងដែលយកព្រះជាទីមួយប៉ុណ្ណោះ។ លោកយ៉ាកុបមានប្រសាសន៍អំពីដំណើរការណ៍នេះយ៉ាងដូច្នេះ៖

តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ
ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង
នោះទ្រង់នឹងប្រទានឲ្យ តែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ
ដ្បិតអ្នកណាដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង។
យ៉ាកុប ១:៥-៦



វាមិនមែនមកពីកាលៈទេសៈរបស់យើង ដែលធ្វើឲ្យយើងអស្ថេរភាពនោះទេ តែគឺជាភាពខ្វះជំនឿរបស់យើងទៅវិញទេ ដែលធ្វើឲ្យយើងគ្មានស្ថេរភាព។ ក្នុងពេលមានវិបត្តិ អ្នកណាដែលធ្វើការសម្រេចចិត្តដោយពឹងលើការដឹកនាំដោយព្រះវិញ្ញាណ អ្នកនោះមិនដែលបោះបង់ចោលការទីពឹងដល់ព្រះម្តងណាឡើយ ទោះបីជាព្រះអង្គហាក់ដូចជានៅស្ងៀមជាងពេលណាផ្សេងទៀតក៏ដោយ។ តែពួកគេក៏នៅតែមានទំនួលខុសត្រូវក្នុងការប្រឈមមុខនឹងស្ថានការណ៍ ទាំងស្វែងរកជំនួយដើម្បីថ្លឹងថ្លែងថាតើទង្វើបែបណាដែលល្អបំផុត ហើយបន្ទាប់មក ក៏ធ្វើការសម្រេចចិត្តដោយមានគំនិតដិតដល់ (មិនពឹងលើអារម្មណ៍) នៅពេលដែលពួកគេត្រូវធ្វើការសម្រេចចិត្ត។ ហើយទន្ទឹមគ្នានោះដែរ ពួកគេក៏ត្រូវតែទុកចិត្តលើព្រះទាំងស្រុង ថាព្រះទ្រង់កំពុងមានព្រះវត្តមានគង់ជាមួយ ហើយក៏កំពុងតែសកម្មក្នុងការដឹកនាំ និងតម្រង់ផ្លូវពួកគេ ហើយជាញឹកញាប់ អាចនិយាយបានថា ទ្រង់កំពុងធ្វើការទាំងនោះនៅពីក្រោយឆាក។

វិធីសាស្រ្តទាំងទទួលខុសត្រូវផងទាំងទុកចិត្តព្រះផង ទាមទារឲ្យមានការរំលែកពេលគ្រប់គ្រាន់ ដើម្បីចំណាយពេលស្ងៀមស្ងាត់ផ្ទាល់ខ្លួន ហើយចំណាយពេលស្តាប់ព្រះសូរសៀងនៃព្រះវិញ្ញាណបរិសុទ្ធ តាមរយៈបទគម្ពីរ និងការអធិស្ឋាន។ យើងនឹងឈោងចាប់ជំនួយខាងក្រៅពីសំណាក់អ្នកណែនាំ គ្រូគង្វាល អាណាព្យាបាល សហការី និងមិត្តសំឡាញ់ណាដែលអាចទុកចិត្តបាន។ តែយើងនឹងមិនព្យាយាមរុញច្រានមហិច្ឆតារបស់ទៅមុខ ដោយមិនខ្វល់ពីសញ្ញាហាមឃាត់នោះឡើយ។ យើងក៏នឹងមិនត្រូវរត់គេចពីការភ័យខ្លាច លើកលែងតែយើងត្រូវតែការពារខ្លួនយើង ពីគ្រោះថ្នាក់ដែលអាចកើតមានខាងមុខភ្លាមៗ។ ហើយយើងក៏មិនត្រូវជាប់គាំង ឬនៅទ្រឹង ដោយមិនព្រមគិតពិចារណា ហើយធ្វើការសម្រេចចិត្តសមហេតុផលក្នុងពេលវេលាសមស្របមួយនោះដែរ។ យើងនឹងងើបភ្នែកឡើងផ្ចង់ទៅចំពោះព្រះយេស៊ូវ ដោយពិចារណាពីគំរូនៃសេចក្តីជំនឿ និងការបម្រើដែលលះបង់របស់ទ្រង់ ក្នុងការរៀបចំដាក់អាទិភាពរបស់យើង។ យើងនឹងទុកចិត្តព្រះឲ្យអស់ពីចិត្តរបស់យើង ហើយបន្ទាប់មក ត្រូវធ្វើសកម្មភាពខណៈពេលដែលយើងអាចមើលឃើញផ្លូវឆ្ពោះទៅមុខកាន់តែច្បាស់ជាងមុន។




*សិក្ខាសាលាភាពជាអ្នកដឹកនាំដែលព្រះវិញ្ញាណទ្រង់នាំ ត្រូវបានធ្វើឡើងសម្រាប់គ្រូគង្វាលចំនួន៥៦នាក់ នៅប្រទេសមីយ៉ាន់ម៉ា (ថ្ងៃទី១០-១៣ ខែមិនា ឆ្នាំ២០២០)។ លោកជីម ស្ថិតក្នុងសំលៀកបំពាក់ប្រពៃណីភូមា ដែលមានភាពសមរម្យសម្រាប់គ្រូបង្រៀន និងអ្នកដឹកនាំ នៅក្នុងវប្បធម៌នោះ។*

*បទពិសោធន៍របស់ខ្ញុំ*

ខែមិនា នៅក្នុងប្រទេសមីយ៉ាន់ម៉ា បានបញ្ជាក់ដល់ខ្ញុំកាន់តែច្បាស់ម្តងទៀតថា ព្រះអង្គពិតជាដឹកនាំ ហើយតម្រង់ផ្លូវ ក្នុងកាលៈទេសៈដែលអស់សង្ឃឹម និងច្របូកច្របល់។ ខ្ញុំត្រូវតែនៅចូលរួមយ៉ាងជិតដល់ ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ហើយខ្ញុំត្រូវគ្រប់គ្រងអារម្មណ៍ចង់វាយបក-គេចវេស-ជាប់គាំង ដើម្បីកុំឲ្យវាយកឈ្នះលើខ្ញុំបាន។ ប៉ុន្តែ ពេលខ្ញុំកាន់តែចង់ថ្វាយសិក្ខសាលា និងការសម្រេចចិត្ត ដាក់ក្នុងព្រះហស្តរបស់ព្រះខ្លាំងប៉ុណ្ណា ហើយពេលខ្ញុំកាន់តែមានចិត្តចង់ស្តាប់ព្រះសូរសៀងដ៏ស្ងៀមស្ងាត់នៃព្រះវិញ្ញាណផង និងស្តាប់សំឡេងអ្នកនៅជុំវិញខ្ញុំផងប៉ុណ្ណា នោះខ្ញុំក៏កាន់តែអាចឮអ្វីដែលខ្ញុំចាំបាច់ត្រូវឮ ព្រមទាំងឃើញអ្វីដែលខ្ញុំចាំបាច់ត្រូវឃើញ។ យូរៗទៅ ចម្លើយនឹងផុសចេញមកឯង។

ព័ត៌មានជើងហោះហើរចុងក្រោយ គឺខុសគ្នាពីស្ថានភាពដែលខ្ញុំធ្លាប់ពិចារណាពីមុន ប៉ុន្តែ លទ្ធផលគឺ១២ថ្ងៃពេញដោយព្រះពរពីព្រះវិញ្ញាណ នៅក្នុងប្រទេសមីយ៉ាន់ម៉ា ហើយក្រោយមក បានវិលទៅជួបជុំគ្រួសារវិញទាន់ពេល។ សប្តាហ៍បញ្ចប់ការសិក្សា នៅឯ MIT គឺប្រកបដោយការភ្ជាប់ទំនាក់ទំនងដ៏មានន័យ និងសម្រាប់ព័ន្ធកិច្ច។ បុគ្គលិកនៃព័ន្ធកិច្ចសាកល សេចក្តីជំនឿ, សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់, Saw Newton ហើយនិងខ្ញុំបានរៀបចំបង្រៀនសិក្ខាសាលា *ភាពជាដឹកដឹកនាំដែលព្រះវិញ្ញាណដឹកនាំ* នៅ Mandalay ដូចដែលបានគ្រោងទុក។ បន្ទាប់មក នៅពេលដែលកាលៈទេសៈស្រាប់តែផ្លាស់ប្តូរភ្លាមៗម្តងទៀត (សង្គ្រាមស៊ីវិល និងវិបត្តិដែលមិនបានរំពឹងទុក) នោះគឺជាពេលដែលត្រូវត្រឡប់ទៅផ្ទះវិញ។ ខ្ញុំបានមកដល់ផ្ទះវិញ មកដល់រង្វង់ដៃដ៏ពោរពេញដោយក្តីស្រឡាញ់នៃ Jill ជាភរិយារបស់ខ្ញុំ បីសប្តាហ៍លឿនជាងផែនការ។ ខ្ញុំមានការដឹងគុណចំពោះរបៀបដែលព្រះទ្រង់បានធ្វើការ តាមរយៈព័ន្ធកិច្ច ហើយមានសន្តិភាពក្នុងចិត្ត ដែលត្រូវលើកចោលកម្មវិធីសិក្ខាសាលាចំនួនពីរទៀត ព្រមទាំងបានដឹងប្រាកដណាស់ថា នៅខណៈពេលនេះ ការនៅផ្ទះគឺពិតជាកន្លែងដែលខ្ញុំត្រូវនៅ។

*មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

ក្នុងពេលដែលមានការចាំបាច់ត្រូវតែធ្វើការសម្រេចចិត្តទាំងពិបាក សូមកុំរំពឹងថា ព្រះទ្រង់នឹងប្រទានឲ្យអ្នក នូវចម្លើយដែលអ្នកកំពុងតែស្វែងរកឲ្យសោះ។ ផ្ទុយទៅវិញ ត្រូវរួបចំណែកពេញទំហឹងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ទន្ទឹមនឹងនោះត្រូវទុកចិត្តថា ព្រះនឹងដឹកនាំអ្នកទៅតាមផ្លូវរបស់ទ្រង់។ ចូរប្រឈមមុខនឹងវិបត្តិ ឬការសម្រេចដែលសំខាន់នៅចំពោះមុខ ទាំងចុះចូលចំពោះបំណងព្រះហឫទ័យរបស់ព្រះ ហើយដោះលែងការប្រកាន់ខ្ជាប់នូវផែនការ និងបំណងប្រាថ្នាដើមរបស់អ្នក រួចទូលសូមនូវសមត្ថភាពអាចមើលឃើញ អ្វីដែលអ្នកចាំបាច់ត្រូវមើលឃើញ។ បន្ទាប់មក កាលណាដល់ពេលដែលត្រូវធ្វើសកម្មភាព នោះចូរកុំខ្លាចដែលត្រូវធ្វើការសម្រេចចិត្ត ឬផ្លាស់ប្តូរផែនការ ប្រសិនបើចាំបាច់។

ទេ អ្នកនឹងមិនតែងតែធ្វើការសម្រេចចិត្តដែល "ត្រឹមត្រូវ" រហូតនោះទេ ប៉ុន្តែ ការថ្លឹកថ្លែងរបស់ត្រូវតែមានការដឹកនាំដោយព្រះវិញ្ញាណកាន់តែច្រើនឡើង ជាមួយនឹងវិធីសាស្រ្ត *ទាំងទទួលខុសត្រូវ ហើយ ទុកចិត្តព្រះ* នេះ។ ហើយ ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ អ្នកនឹងរៀនបានមេរៀនថ្មី ចេញពីបទពិសោធន៍របស់អ្នក។ ខណៈពេលដែលអ្នកមានចំណែកក្នុងការងារដ៏លំបាក នៃការធ្វើការសម្រេចដែលពិបាកៗ ដោយមានការស្វែងរកព្រះយ៉ាងស្មោះត្រង់ ក្នុងការអធិស្ឋាន ព្រមទាំងទុកចិត្តព្រះអស់អំពីចិត្ត នោះជំនឿរបស់នឹងលូតលាស់ឡើងផងដែរ។ អ្នកនឹងកាន់តែរឹងមាំឡើង ហើយកាន់តែអាចបម្រើការងារជាអ្នកដឹកនាំ ដោយមានព្រះវិញ្ញាណបរិសុទ្ធទ្រង់នាំ ក្នុងសហគមន៍របស់អ្នក ក្នុងពេលដែលពួកគេត្រូវការបំផុត។

កម្រងសំណេរតែងសេចក្តី "តើយើងអាចរំពឹងអ្វីពីព្រះនៅពេលឥឡូវនេះ?" ត្រូវបានចងក្រងឡើង ដើម្បីជាការឆ្លើយតបទៅកាន់វិបត្តិជាសាកលឆ្នាំ២០២០ នៃជំងឺកូវីដ១៩។ សំណេរនេះផ្តោតលើរបៀបដែលអ្នកជឿអាចទុកចិត្តព្រះខ្លាំងជាងមុន ក្នុងពេលដែលជួបប្រទះនឹងបញ្ហា។ សំណេរតែងសេចក្តីនេះមានពន្យល់បន្ថែម ស្តីពីអនុសាសន៍សម្រាប់ជូនជាការអនុវត្ត ដែលបានផ្តល់ជូន នៅក្នុងជំពូកទីប្រាំបី "ការទុកចិត្តព្រះ" ក្នុងសៀវភៅដែលមានចំណងជើងថា *THE SPIRIT-LED LEADER: NINE LEADERSHIP PRACTICES AND SOUL PRINCIPLES* (HERNDON, VA: ALBAN INSTITUTE, ឆ្នាំ2005), ទំព័រ 184-190.